ប្រព្រឹត្តប័ត្រព័ត៌មានសង្ខេប

សប្តាហ៍ដែលបញ្ចប់
ថ្ងៃទី២១ ខែកញ្ញា ២០១៨

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- ភាគីពាក់ព័ន្ធបន្តការចរចាប្រាក់ឈ្នួលអប្បបរមាវិស័យកាត់ដេរសម្រាប់ឆ្នាំ២០១៩ ក្នុងប្រទេសកម្ពុជា
- បណ្តាប្រទេសអ្នកមានកំពុងរីករាយជាមួយនឹងកំណើនប្រាក់ខែ
- បណ្តារដ្ឋជាច្រើនរបស់សហរដ្ឋអាមេរិចខ្វះទុនបម្រុងដើម្បីទប់ទល់នឹងឱនភាពសេដ្ឋកិច្ចនាពេលខាងមុខ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ភាគីពាក់ព័ន្ធបន្តការចរចាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌសម្រាប់ឆ្នាំ២០១៩

គណៈកម្មការប្រឹក្សាការងារ ដែលមានសមាសភាពតំណាងរាជរដ្ឋាភិបាល កម្មករនិយោជិត (សហជីព) និងនិយោជក បានបន្តកិច្ចពិភាក្សាចរចាប្រាក់ឈ្នួលអប្បបរមានៅឆ្នាំក្រោយ សម្រាប់កម្មករនិយោជិតក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ វាយនភណ្ឌ និងផលិតស្បែកជើង នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ភាគីសហជីពស្នើប្រាក់ឈ្នួលអប្បបរមាចំនួន ១៨៩ដុល្លារអាមេរិកក្នុងមួយខែ ខណៈភាគីនិយោជកបានផ្តល់១៧៦ដុល្លារអាមេរិក។ តំណាងរដ្ឋាភិបាលបានសម្របសម្រួលកិច្ចប្រជុំពិភាក្សា និងបានស្នើនូវតួលេខចំនួន១៧៧ដុល្លារអាមេរិកក្នុងមួយខែ។

### តារាងប្រចាំសប្តាហ៍៖ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៨

យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហភាពអឺរ៉ុប គឺជាទីផ្សារនាំចេញទំនិញដ៏ធំបំផុតរបស់ប្រទេសកម្ពុជា ដែលមានទំហំ ១.០៧៧លានដុល្លារអាមេរិក ក្នុងត្រីមាសទី១នៅឆ្នាំ២០១៨នេះ ពោលគឺកើនឡើងប្រមាណ ១០,៣ភាគរយ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ស្របពេលនោះដែរ ការនាំចេញទៅសហរដ្ឋអាមេរិកក៏បានកើនឡើងខ្លាំង រហូតដល់ ៦៥៥លានដុល្លារអាមេរិក ក្នុងត្រីមាសទី១ នៅឆ្នាំ២០១៨ ដែលកើនពី ៥៣៨លានដុល្លារអាមេរិក នៅត្រីមាសទី១ នៅឆ្នាំ២០១៧ ដែលមានកំណើនប្រមាណ ២២ភាគរយ។ ប្រទេសជប៉ុន និងអាស៊ាននៅតែបន្តជាទីផ្សារដ៏ធំសម្រាប់ការនាំចេញរបស់កម្ពុជា ដែលទំនិញនាំចេញទាំងនោះភាគច្រើនជាផលិតផលសម្លៀកបំពាក់ និងស្បែកជើង។

**ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៨ (គិតជាលានដុល្លារអាមេរិក)**




ប្រភពៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៨

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## បណ្តាប្រទេសអ្នកមានកំពុងតែរីករាយជាមួយនឹងកំណើនប្រាក់ខែ

ផ្អែកទៅតាមការវិភាគរបស់ JP Morgan Chase & Co., កំណើនប្រាក់ខែនៅក្នុងសហភាពអឺរ៉ុប សហរដ្ឋអាមេរិក និងប្រទេសជប៉ុន បានកើនឡើងដល់ទៅ ២,៥ភាគរយនៅក្នុងត្រីមាសទី២ឆ្នាំ២០១៨។ កំណើនប្រាក់ខែនេះជាកំណើនដ៏លឿនមួយចាប់តាំងពីវិបត្តិសេដ្ឋកិច្ចពិភពលោកកាលពីឆ្នាំ២០០៩។

ក្រុមអ្នកវិភាគ បានធ្វើការសន្និដ្ឋានដោយផ្អែកលើការធ្លាក់ចុះនៃចំនួនអ្នកអត់ការងារធ្វើ។ ពួកគេក៏បានព្យាករណ៍ថា កំណើនប្រាក់ខែនឹងកើនឡើងដល់ ៣ភាគរយនៅឆ្នាំក្រោយ ។

ការកើនឡើងនៃតម្រូវការរបស់ប្រជាពលរដ្ឋនៅបណ្តាប្រទេសលោកខាងលិច នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាប្រទេសផលិតទំនិញប្រើប្រាស់ ដូចជាផលិតផលសម្លៀកបំពាក់នៅក្នុងប្រទេសកម្ពុជាជាដើម។

## ការនាំចេញរបស់ជប៉ុន និងការដឹកទំនិញទៅសហរដ្ឋអាមេរិកកើនឡើង ខណៈដែលសង្គ្រាមពាណិជ្ជកម្មគឺជាក្តីបារម្ភ

យោងតាមទិន្នន័យពាណិជ្ជកម្មរបស់ ក្រសួងហិរញ្ញវត្ថុប្រទេសជប៉ុន បើគិតត្រឹមខែសីហា ការនាំចេញរបស់ជប៉ុនបានកើនឡើង ៦,៦ភាគរយធៀបទៅនឹងឆ្នាំមុនៗ។ សន្ទុះកំណើននេះ មួយផ្នែកធំគឺដោយសារការនាំចេញរបស់ជប៉ុនទៅសហរដ្ឋអាមេរិក មានការកើនឡើងប្រមាណជា៥,៣ភាគរយ ដែលក្នុងនោះផលិតផលភាគច្រើនជាថ្នាំពេទ្យ គ្រឿងសំណង់ និងគ្រឿងចក្រជីករករ៉ែ។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## បណ្តារដ្ឋជាច្រើនរបស់សហរដ្ឋអាមេរិចខ្វះទុនបម្រុងដើម្បីទប់ទល់នឹងវិបត្តិភាពសេដ្ឋកិច្ចនាពេលខាងមុខ

យោងតាមរបាយការណ៍របស់ S&P Global Ratings កាលពីថ្ងៃច័ន្ទបានបង្ហាញថា ក្នុងបណ្តារដ្ឋទាំងអស់នៅក្នុងសហរដ្ឋអាមេរិកមានរដ្ឋចំនួនតិចជាងពាក់កណ្តាលប៉ុណ្ណោះ ដែលមានទុនបម្រុងហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីទប់ទល់នឹងវិបត្តិភាពសេដ្ឋកិច្ចកម្រិតមធ្យមដែលអាចនឹងកើតឡើងនាពេលខាងមុខនេះ បើទោះបីជាហិរញ្ញវត្ថុផ្នែកសុខាភិបាលត្រូវបានពង្រឹងនៅឆ្នាំ២០១៨នេះក៏ដោយ។ ទុនបម្រុងរបស់រដ្ឋចំនួនតែ២០រដ្ឋប៉ុណ្ណោះ ដែលអាចទប់ទល់នឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចដោយមិនមានការកាត់បន្ថយការចំណាយ ឬបង្កើនពន្ធ។ បណ្តារដ្ឋភាគច្រើនទៀតបានប្រឈមនឹងទុនបម្រុងមានកម្រិតដោយសារតែការថយចុះនូវចំណូល និងការកើនឡើងចំណាយខ្ពស់ ជាពិសេស ការទូទាត់បំណុល ការរួមចំណែកសោធននិវត្តន៍ និងការចំណាយលើសង្គមជាដើម។

# ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈ ការសម្រេចចិត្តនៃអត្រាការប្រាក់របស់សហរដ្ឋអាមេរិក ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងតៃវ៉ាន់។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្ដាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២៤ ខែកញ្ញា</u>

- អត្រាអតិផរណារបស់សឹង្ហបុរី ខែសីហា
- តុល្យភាពថវិការរបស់ហ្វីលីពីន ខែសីហា
- សន្ទស្សន៍នៃការផលិតរបស់ធនាគារជាតិនៃរដ្ឋដាឡាស ស.ហ.អ (U.S Dallas Fed Manufacturing Index) ខែកញ្ញា

<u>ថ្ងៃអង្គារ ទី២៥ ខែកញ្ញា</u>

- កំណត់ហេតុកិច្ចប្រជុំស្ដីពីគោលនយោបាយហិរញ្ញវត្ថុរបស់ប្រទេសជប៉ុន
- ផលិតផលឧស្សាហកម្មរបស់ប្រទេសថៃ ខែសីហា
- ទិន្នន័យលក់រាយរបស់តៃវ៉ាន់ ខែសីហា
- អត្រាអ្នកអត់ការងារធ្វើនៅតៃវ៉ាន់ ខែសីហា
- សៀវភៅក្រហមរបស់ ស.ហ.អ សំរាប់ថ្ងៃទី២២ ខែកញ្ញា

<u>ថ្ងៃពុធ ទី២៦ ខែកញ្ញា</u>

- ផលិតផលឧស្សាហកម្មរបស់ប្រទេសសឹង្ហបុរី ខែសីហា
- ទិន្នន័យវិនិយោគពីបរទេសរបស់វៀតណាម ខែកញ្ញា
- ទិន្នន័យស្តុកប្រេងឆៅរបស់វិទ្យាស្ថានប្រេងរបស់ ស.ហ.អ (API) សំរាប់ថ្ងៃទី២១ ខែកញ្ញា

<u>ថ្ងៃព្រហស្បិ៍ ទី២៧ ខែកញ្ញា</u>

- សេចក្ដីសម្រេចស្ដីពីអត្រាការប្រាក់របស់ធនាគារសហព័ន្ធនៅ ស.ហ.អ
- ប្រាក់ចំណេញផ្នែកឧស្សាហកម្មរបស់ចិន ខែសីហា
- អត្រាអ្នកអត់ការងារធ្វើនៅប្រទេសថៃ ខែសីហា
- សេចក្ដីសម្រេចស្ដីពីអត្រាការប្រាក់របស់ហ្វីលីពីន
- សេចក្ដីសម្រេចស្ដីពីអត្រាការប្រាក់របស់ឥណ្ឌូនេស៊ី
- សេចក្ដីសម្រេចស្ដីពីអត្រាការប្រាក់របស់តៃវ៉ាន់
- ទិន្នផលជាតិសរុប (GDP) របស់ ស.ហ.អ សំរាប់ត្រីមាសទី២ ឆ្នាំ២០១៨

<u>ថ្ងៃសុក្រ ទី២៨ ខែកញ្ញា</u>

- អតិផរណារបស់ជប៉ុន ខែកញ្ញា
- អត្រាអ្នកអត់ការងារធ្វើនៅជប៉ុន ខែសីហា
- កំណើនផលទុនជាតិសរុប (GDP growth) របស់វៀតណាម សំរាប់ត្រីមាសទី៣ ឆ្នាំ២០១៨ និងទិន្នន័យផលិតផលឧស្សាហកម្ម អតិផរណា និងទិន្នន័យលក់រាយរបស់វៀតណាម ខែកញ្ញា
- ចំណូល និងចំណាយរបស់មនុស្សម្នាក់នៅក្នុង ស.ហ.អ ខែសីហា
- សន្ទស្សន៍តម្លៃផលិតកម្មរបស់ប្រទេសម៉ាឡេស៊ី ខែសីហា
- គណនេយ្យចរន្តរបស់ប្រទេសថៃ ខែសីហា
- ទិន្នន័យលក់រាយរបស់ប្រទេសថៃ ខែមិថុនា និងខែកក្កដា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ព្រុយណេ ខែមិថុនា និងខែកក្កដា
- កំណើនផលទុនជាតិសរុប (GDP growth) របស់ព្រុយណេ សំរាប់ត្រីមាសទី២ ឆ្នាំ២០១៨